# បញ្ហាប្រឈម និងសំណូមពររបស់អង្គការសង្គមស៊ីវិល
# សម្រាប់វេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយអង្គការសង្គមស៊ីវិល
## (លើកទី០៦)
## ថ្ងៃទី១១ ខែធ្នូ ២០២៤
## ទីកន្លែង៖ ក្រសួងមហាផ្ទៃ

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ហៅកាត់ថា គ.ស.ក. បានសហការជាមួយអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងការសម្របសម្រួលប្រមូលសំណើ សំណូមពរ ក្តីកង្វល់ និងអនុសាសន៍ ពីអង្គការសង្គមស៊ីវិលទាំងថ្នាក់ជាតិ និងក្រោមជាតិ តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ដោយផ្ទាល់ ព្រមទាំងការផ្តល់ធាតុចូលសំខាន់ៗពីសង្គមស៊ីវិលតាមអនឡាញ ដើម្បីដាក់ជូនក្នុងវេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល(លើកទី៦) ដែលនឹងរៀបចំឡើងនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ ខាងមុខនេះ។ វេទិកាភាពជាដៃគូផ្តល់នូវវេទិកាដ៏មានតម្លៃសម្រាប់អង្គការសង្គមស៊ីវិល និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធរបស់រដ្ឋាភិបាលក្នុងការចូលរួមក្នុងកិច្ចសន្ទនាក្នុងន័យស្ថាបនា ដោះស្រាយបញ្ហាប្រឈមសំខាន់ៗ និងរួមគ្នាបង្កើតដំណោះស្រាយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។

| បញ្ហាប្រឈម និងកង្វល់របស់អង្គការសង្គមស៊ីវិល | សំណូមពរ និងអនុសាសន៍ របស់អង្គការសង្គមស៊ីវិល |
|---|---|
| **ផ្នែកទី១៖ ការបង្កើត និងការចុះបញ្ជីសមាគម និង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក** | |
| – ដំណើរការជូនដំណឹងអំពីការប្រែប្រួល ឬផ្លាស់ប្តូរប្រធាន/នាយកប្រតិបត្តិ ឬអាស័យដ្ឋានរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិក្រសួងតម្រូវឱ្យសរសេរលិខិតជាលាយលក្ខណ៍អក្សរដាក់ជូនរដ្ឋមន្រ្តី និងឆ្លងកាត់នីតិវិធី និងឯកសារយោងច្រើនដែលធ្វើឱ្យចំណាយពេលវេលាយូរ និងមានការលំបាក សម្រាប់**សមាគម និងអង្គការមិនមែនរដ្ឋាភិ**នៅថ្នាក់ក្រោមជាតិ តម្រូវឱ្យចាំបាច់ត្រូវឡើងមកក្រសួងមហាផ្ទៃ ធ្វើឱ្យរាំងស្ទះដល់នីតិវិធីបន្តក្នុងការបំពេញកាតព្វកិច្ចផ្សេងៗទៀតជាមួយក្រសួងដែលពាក់ព័ន្ធ ក្នុងនោះមាន អគ្គនាយកដ្ឋានពន្ធដារ និង និយ័តករគណនេយ្យនិងសវនកម្ម ជាដើម។<br>– មានករណីកើតឡើងជាក់ស្តែង ក្រសួងមហាផ្ទៃ តម្រូវឱ្យអង្គការមិនមែនរដ្ឋាភិបាលកែប្រែលក្ខន្តិកៈរបស់ខ្លួន ពេលជូនដំណឹងអំពីការប្តូរប្រធាន/នាយកប្រតិបត្តិ ឬអាស័យដ្ឋាន ដែលធ្វើឱ្យបាត់បង់អត្តសញ្ញាណ ភាពជាម្ចាស់ នៃលក្ខន្តិកៈដែលបានបោះឆ្នោតសម្រេចពីស្ថាប័នរួចហើយ។ | – ស្នើសុំរាជរដ្ឋាភិបាលអនុញ្ញាតិ និងសម្របសម្រួលនីតិវិធីក្នុងការធ្វើបច្ចុប្បន្នភាពពីការផ្លាស់ប្តូរអាស័យដ្ឋាន ឬផ្លាស់ប្តូរ ប្រធាន/នាយកប្រតិបត្តិរបស់ខ្លួន ឬការដាក់ឯកសារ ឬការដាក់លិខិតជូនដំណឹងផ្សេងៗ សូមធ្វើតាមប្រព័ន្ធអនឡាញ និងណែនាំអំពីនីតិវិធីក្នុងការអនុវត្ត និងបញ្ជីឯកសារដែលត្រូវភ្ជាប់ជូនឱ្យបានជាក់លាក់។<br>– សុំផ្តល់ពេលវេលាគ្រប់គ្រាន់ និងហេតុផលជាក់លាក់ ប្រសិនបើក្រសួងមហាផ្ទៃតម្រូវឱ្យធ្វើការកែប្រែលក្ខន្តិកៈដែលបានអនុម័តរួចពីស្ថាប័ន ដែលបានដាក់ជូនក្រសួង។<br>– ប្រសិនបើមានការតម្រូវឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ធ្វើការកែតម្រូវ ឬដាក់បន្ថែមឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត សុំផ្តល់ព័ត៌មានត្រឡប់មកឱ្យទាន់ពេលវេលា ដើម្បី មាន |

| | |
|---|---|
| | ពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំឯកសារទាំងនោះ។<br>– ប្រសិនបើមានការតម្រូវឱ្យបង់កម្រៃ ឬសេវាផ្សេងៗ សុំឱ្យមានជាតារាងបញ្ជីសេវាជាសាធារណៈ និងមានវិក្កយបត្រត្រឹមត្រូវ ជៀសវៀងកម្រៃសេវាក្រៅផ្លូវការផ្សេងៗ។ |
| **ផ្នែកទី២៖ ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស** | |
| – ការចុះ និងបន្តអនុស្សារណៈនៃការយោគយល់គ្នា (MOU) សម្រាប់ការអនុវត្តគម្រោង និង/ឬសម្រាប់ស្ថាប័ន រវាង**សមាគម និងអង្គការមិនមែនរដ្ឋាភិបរទេស**ជាមួយក្រសួងនានាមានបែបបទ និងស្តង់ដារផ្សេងៗ គ្នា ដែលធ្វើឲ្យមានការពិបាកក្នុងការអនុវត្ត។ | – ស្នើសុំរាជរដ្ឋាភិបាលធ្វើសុខដុមរមនា និងសមាហរណកម្មការចុះអនុស្សារណៈ នៃការយោគយល់គ្នា (MOU) សម្រាប់ការអនុវត្តគម្រោង និង/ឬសម្រាប់ស្ថាប័ន រវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបរទេសជាមួយក្រសួងនានាតាមប្រតាមប្រព័ន្ធអនឡាញ និងជាប្រព័ន្ធតែមួយ។<br>– ស្នើសុំរាជរដ្ឋាភិបាលអនុញ្ញាតិ និងសម្របសម្រួលនីតិវិធីក្នុងការបន្តអនុស្សារណៈនៃការយោគយល់គ្នា (MOU) និងឯកសារយោងផ្សេងៗ សុំធ្វើតាមប្រព័ន្ធអនឡាញ ដើម្បីសម្រួល និងកាត់បន្ថយការចំណាយផ្សេងៗ។<br>– ស្នើសុំការណែនាំ នីតិវិធីជាក់លាក់ និងមានបញ្ជីឯកសារដែលត្រូវភ្ជាប់អោយបានច្បាស់លាស់ ដើម្បីងាយស្រួលសម្រាប់អ្នកអនុវត្ត។<br>– ប្រសិនបើមានការតម្រូវឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបរទេស ធ្វើការកែតម្រូវ ឬបន្ថែមឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត សុំផ្តល់ព័ត៌មានត្រឡប់មកឱ្យទាន់ពេលវេលា ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំឯកសារទាំងនោះ។<br>– ប្រសិនបើមានការតម្រូវឱ្យបង់កម្រៃ ឬសេវាផ្សេងៗ សុំឱ្យមានជាតារាងបញ្ជីសេវាជាសាធារណៈ និងមានវិក្កយបត្រត្រឹមត្រូវ ជៀសវៀងកម្រៃសេវាក្រៅផ្លូវការផ្សេងៗ។ |
| **ផ្នែកទី៣៖ សិទ្ធិ ផលប្រយោជន៍ និងកាតព្វកិច្ចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល** | |
| – **អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅថ្នាក់ក្រោមជាតិ**ជួបបញ្ហាប្រឈមក្នុងការបំពេញកាតព្វកិច្ចដាក់របាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ ជូនក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច | – ស្នើសុំរាជរដ្ឋាភិបាលអនុញ្ញាតិ និងសម្របសម្រួលនីតិវិធីក្នុងការដាក់របាយការណ៍សកម្មភាព របាយការណ៍ហិរញ្ញវត្ថុ ការធ្វើបច្ចុប្បន្នភាព ការដាក់ឯក |

ហិរញ្ញវត្ថុ និងកាតព្វកិច្ច ផ្សេងៗទៀតដែលកំណត់ដោយច្បាប់ទាំងអស់នោះ ដែលត្រូវចំណាយពេលវេលា ថវិកាក្នុងការធ្វើដំណើរ និងឯកសារតម្រូវច្រើន ។

- អាជ្ញាធរមួយចំនួននៅថ្នាក់ជាតិ និងក្រោមជាតិ នៅតែតម្រូវឱ្យ**សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**ដាក់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬលិខិតស្នើសុំកិច្ចសហប្រតិបត្តិការ ទោះបី**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះ**បានចុះបញ្ជី និងអនុស្សារណៈនៃការយោគយល់រួចហើយក៏ដោយ។
- អាជ្ញធរមួយចំនួននៅថ្នាក់ជាតិ និងក្រោមជាតិ នៅតែបន្តឃ្លាំមើល សាកសួរ មកថតរូប វីដេអូ ថតយកបញ្ជីវត្តមានអ្នកចូលរួម ថតចម្លងឯកសារ ថតសំឡេងរបស់អ្នកចូលរួមក្នុងសិក្ខាសាលាឬវេទិកាសាធារណៈ និងកិច្ចប្រជុំ តាមរយៈការតម្រូវឱ្យបុគ្គលិកភោជនីយដ្ឋាន និងសណ្ឋាគារឯកជន ធ្វើការរាយការណ៍ទៅប៉ូលីស និងអាជ្ញាធរមូលដ្ឋានផងដែរ។ (**ករណីជាក់ស្តែងទី១៖** អង្គការដៃគូមួយបានរៀបចំកិច្ចសន្ទនាពហុភាគីស្តីពីខ្សែសង្វាក់តម្លៃរមនៃចេក និងកៅស៊ូនៅកម្ពុជា កាលពីថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០២៤ នៅខេត្តកំពង់ចាម។ អង្គការដៃគូនោះបានដាក់លិខិតអញ្ជើញជូនរដ្ឋបាលខេត្ត ២ សប្តាហ៍មុនការរៀបចំ ប៉ុន្តែមួយថ្ងៃមុនកម្មវិធី រដ្ឋបាលខេត្តបានឆ្លើយតបថា គាត់មិនអាចបញ្ជូនមន្ត្រីខេត្ត (មន្ទីរខេត្ត) ចូលរួមព្រឹត្តិការណ៍បានទេ លុះត្រាតែអ្នករៀបចំដាក់លិខិតអញ្ជើញទៅក្រសួងមហាផ្ទៃជាមុនសិន។ បន្ទាប់មកក្រសួងមហាផ្ទៃ ប្រគល់លិខិតទៅរដ្ឋបាលខេត្ត ទើបគាត់អាចចាត់មន្ត្រីខេត្តឱ្យចូលរួមក្នុងពិធីនោះបាន។)
- (**ករណីជាក់ស្តែងទី២៖** អង្គការដៃគូមួយទៀត ក៏ជួបប្រទះទៅនឹងករណីដូចគ្នានេះដែរ។ អង្គការដែលធ្វើការលើវិស័យលើកកម្ពស់សិទ្ធិមនុស្ស និងការពារបរិស្ថាន មានការពិបាក ក្នុងការអនុវត្តគម្រោងការងាររបស់ខ្លួន។)
- (**ករណីជាក់ស្តែងទី៣៖** អង្គការក្នុងស្រុកមួយដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃរួចហើយ ។អង្គការនោះមាន បុគ្គលិកស្ម័គ្រចិត្តជាជនបរទេស។ បុគ្គលិកស្ម័គ្រចិត្តជាជនបរទេសចុះធ្វើការនៅខេត្តមណ្ឌលគិរី ត្រូវបានអាជ្ញធរចុះហាមឃាត់ ដោយសារអាជ្ញាធរអះអាងថាអង្គការនោះពុំមានការិយាល័យសាខានៅតាមខេត្ត ដែលបានការអនុញ្ញាតិពីខេត្ត។

សារ ឬការដាក់លិខិតជូនដំណឹងផ្សេងៗសូមធ្វើតាមប្រព័ន្ធអនឡាញ ដើម្បីសម្រួល និងកាត់បន្ថយការចំណាយផ្សេងៗ។

- ស្នើអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបន្ត និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលលើគ្រប់វិស័យក្នុងនោះមាន វិស័យសិទ្ធិមនុស្ស សិទ្ធិដីធ្លី បរិស្ថាន ធនធានធម្មជាតិ អប់រំ សុខាភិបាល អភិបាលកិច្ច និងវិស័យផ្សេងៗទៀត ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។
- ស្នើសុំឱ្យរដ្ឋាភិបាលលើកកម្ពស់សិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋគ្រប់រូប និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង សិទ្ធិ សេរីភាព ដែលបានកំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។
- ស្នើក្រសួងមហាផ្ទៃ និងក្រុមការងាររាជរដ្ឋាភិបាលបន្ត និងពង្រឹងកិច្ចសហប្រតិបត្តិ ក្នុងដំណើរការប្រមូលធាតុចូលក្នុងការស្នើធ្វើវិសោធនកម្មលើមាត្រាមួយចំនួននៃច្បាប់ស្តីពីសមាគមន និងអង្គការមិនមែនរដ្ឋាភិបាល។
- ស្នើក្រសួងមហាផ្ទៃ និងក្រុមការងាររាជរដ្ឋាភិបាលត្រួតពិនិត្យ និងទទួលយកធាតុចូលពីអង្គការសង្គមស៊ីវិលលើការស្នើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានដាក់ជូនក្រសួងមហាផ្ទៃរួចមកហើយកាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ នេះ។
- ស្នើសុំលើកលែងពន្ធប្រាក់ចំណូលនិងអាករលើតម្លៃបន្ថែមទាំងអស់ពីសហគ្រាសសង្គម និងមូលនិធិគម្រោងទាំងអស់ដែលគាំទ្រដល់បេសកកម្មនិងប្រតិបត្តិការរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

| | |
|---|---|
| | – ស្នើសុំក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងក្រសួងដែលពាក់ព័ន្ធផ្សេងៗទៀត សម្របសម្រួល ផ្តល់ព័ត៌មាន ផ្តល់ឱកាសក្នុងការឆ្លើយតប ឬចូលឆ្លើយបំភ្លឺ ឬពិន័យរដ្ឋបាល ក្នុងករណីដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ខកខាន ឬមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានពេញលេញដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម រួមទាំងកាតព្វកិច្ចផ្សេងៗទៀត។<br>– ពង្រឹងយន្តការនៃការប្រាស្រ័យទាក់ទងរវាងអង្គការសង្គមស៊ីវិល និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដោះស្រាយការយល់ច្រឡំ បង្កើនទំនុកចិត្ត និងពង្រឹងភាពជាដៃគូ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល។ |
| **ផ្នែកទី៤៖ ការផ្អាកសកម្មភាព ការរំលាយ ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល** | |
| – អាជ្ញាធរមូលដ្ឋានបានមកសួរសំណួរ និងមើលបញ្ជីអ្នកចូលរួមវគ្គបណ្តុះបណ្តាលកាលពីឆ្នាំមុន។<br>– អ្នកសារព័ត៌មាន ក៏បានប្រឈមមុខនឹងការសួរសំណួរ និងការទាមទារពីមន្ត្រីរដ្ឋាភិបាល នៅពេលដែលពួកគេសួរសំណួរដើម្បីសរសេរព័ត៌មាន ព្រមទាំងមានពាក្យបណ្តឹងលើអ្នកសារព័ត៌មានផងដែរ ដែលធ្វើឱ្យសេរីភាពសារព័ត៌មានរួមតូច។<br>– អាជ្ញាធរមួយចំនួននៅថ្នាក់ក្រោមជាតិមួយចំនួននៅតែតម្រូវឱ្យ**សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**ក្នុងស្រុកចុះអនុស្សារណៈនៃការយោគយល់គ្នាសម្រាប់គម្រោង ឬស្ថាប័នរវាង**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះ**ជាមួយមន្ទីរ ឬស្ថាប័ននៅខេត្តគោលដៅនៃប្រតិបត្តិការរបស់ខ្លួន។ | – ស្នើសុំឱ្យរដ្ឋាភិបាលលើកកម្ពស់សិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋគ្រប់រូប និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងសិទ្ធិសេរីភាពដូចដែលបានកំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។<br>– ស្នើអាជ្ញាធរថ្នាក់ជាតិ ក្រោមជាតិ បន្ត និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលលើគ្រប់វិស័យក្នុងនោះមានវិស័យសិទ្ធិមនុស្ស សិទ្ធិដីធ្លី បរិស្ថាន ធនធានធម្មជាតិ អប់រំ សុខាភិបាល វិស័យផ្សេងៗទៀត ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។ |
| **ផ្នែកទី៥៖ វិធានការរដ្ឋបាល និងកិច្ចសហប្រតិបត្តិការ** | |
| – **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**មានការលំបាក និងត្រូវចំណាយពេលវេលាច្រើនក្នុងការស្នើសុំធ្វើស្លាកលេខយានយន្តរបស់អង្គការ។<br>– **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ដាក់លិខិតអញ្ជើញអាជ្ញាធរមូលដ្ឋានដូចជា មេភូមិ មេឃុំ ឬមន្ទីរ អាជ្ញាធរទាំងនោះតម្រូវ | – ស្នើសុំគោលការណ៍ណែនាំរួមរវាងស្ថាប័នដែលពាក់ព័ន្ធដូចជាក្រសួងមហាផ្ទៃ និងក្រសួងសាធារណៈការ និងដឹកជញ្ជូន ដើម្បីពន្លឿនដំណើរស្នើសុំនិងចុះឈ្មោះសម្រាប់ធ្វើស្លាកលេខយានយន្តរបស់អង្គការ។ |

| | |
|---|---|
| ឱ្យ**សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ត្រូវតែដាក់លិខិតទៅស្នើសុំពីអភិបាលខេត្ត ទើបគាត់មកចូលរួមកម្មវិធី និងកិច្ចសហប្រតិបត្តិការផ្សេងៗ។ ក្នុងករណីខ្លះ អាជ្ញាធរមិនឆ្លើយតបចំពោះលិខិតអញ្ជើញរបស់**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះ** ឡើយ។ | – ស្នើសុំក្រសួងមហាផ្ទៃបន្ត និងពង្រីកការអប់រំ និងផ្សព្វផ្សាយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដល់មន្ត្រី និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ពិសេសអាជ្ញាធរថ្នាក់ខេត្ត ស្រុក ឃុំ អោយបានទូលំទូលាយ។<br>– ស្នើសុំក្រសួងមហាផ្ទៃ និងក្រសួងដែលពាក់ព័ន្ធបន្តពង្រីកការអប់រំ និងផ្សព្វផ្សាយលើកកម្ពស់អក្ខរកម្មឌីជីថល និងសន្តិសុខតាមអ៊ីនធឺណិតទៅកាន់អាជ្ញាធរគ្រប់ជាន់ថ្នាក់ ពិសេសអាជ្ញាធរថ្នាក់ខេត្ត ស្រុក ឃុំ អោយបានទូលំទូលាយ ចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងអភិបាលកិច្ច និងការផ្សព្វផ្សាយដល់ប្រជាពលទូទៅនៅថ្នាក់មូលដ្ឋានរបស់ខ្លួន។<br>– ស្នើសុំក្រសួងមហាផ្ទៃបន្តរៀបចំវេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយអង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិឱ្យបានទៀងទាត់ និងពីរដងក្នុងមួយឆ្នាំ។<br>– ស្នើសុំក្រសួងមហាផ្ទៃបន្ត និងជំរុញអាជ្ញាធរថ្នាក់ក្រោមជាតិ ពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីរៀបចំវេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិឱ្យបានទៀងទាត់ និងពីរដងក្នុងមួយឆ្នាំ ដើម្បីបង្កើនការសហការក្នុងការតាមដាន ត្រួតពិនិត្យ ចូលរួមក្នុងការអនុវត្ត ច្បាប់ និងគោលនយោបាយ។<br>– ស្នើរដ្ឋាភិបាលផ្តល់ការណែនាំជាក់លាក់ និងបង្កើតឱ្យមានជនបង្គោល បង្កើតការិយាល័យទទួលខុសត្រូវផ្តល់ការគាំទ្រដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងដំណើរការអនុលោមភាពច្បាប់ និងបង្កើតការិយាល័យ ច្រកចេញចូលតែមួយ ដើម្បីដោះស្រាយ និងទទួលបណ្តឹងផងដែរ។<br>– ស្នើរដ្ឋាភិបាលផ្តល់មូលនិធិបន្តដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងរួមគ្នា ក្នុងករណីគម្រោងសកម្មភាពដែលរដ្ឋាភិបាលមិនអាចអនុវត្តតែឯងបាន។<br>– ស្នើសុំរដ្ឋាភិបាលពិចារណាក្នុងការចូលរួមក្នុងវេទិកាភាពជាដៃគូសកល របស់អង្គការសង្គមស៊ីវិល និងរដ្ឋា |

| | |
|---|---|
| | ភិបាល ដែលហៅថា ភាពជាដៃគូរដ្ឋាភិបាលបើកចំហ Open Government Partnership ( OGP ) រួមមានប្រទេសចំនួន ៧៧ និងរដ្ឋាភិបាលក្នុងតំបន់ចំនួន ១៥០ ដែលតំណាងឱ្យមនុស្សជាងពីរពាន់លាននាក់ និងអង្គការសង្គមស៊ីវិលរាប់ពាន់។<br>– ស្នើឱ្យបង្កើតយន្តការផ្តល់មតិរួមសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាល តាមរយៈការបើកចំហរទិន្នន័យ ដើម្បីត្រួតពិនិត្យ និងដោះស្រាយគម្លាតក្នុងការអនុវត្តគោលនយោបាយគាំពារកុមារ និងសិទ្ធិមនុស្ស។<br>– ស្នើសុំរដ្ឋាភិបាលលើកកម្ពស់សេរីភាពនៃការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិទទួលបានព័ត៌មាន ជាពិសេសសម្រាប់អង្គការសង្គមស៊ីវិលដែលធ្វើការលើគម្រោងដែលពាក់ព័ន្ធនឹងកុមារ។<br>– ស្នើសុំរដ្ឋាភិបាលបន្ត និងបង្កើតយន្តការ ដែលមានការចូលរួមពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ដែលធ្វើលើវិស័យអប់រំនិងសិទ្ធិកុមារ ក្នុងដំណើរការតាក់តែង រៀបចំច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធកុមារ ដែលក្នុងនោះច្បាប់ស្តីពីការការពារកុមារ និងបទប្បញ្ញត្តិស្តីពីសុវត្ថិភាពកុមារតាមអ៊ីនធឺណិត។<br>– ស្នើសុំរដ្ឋាភិបាលបន្ត និងដាក់ចេញនូវយន្តការនានាដើម្បីឱ្យមានការចូលរួមប្រកបដោយអត្ថន័យពីតំណាងកុមារ និងតំណាងយុវជនក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយអត្ថន័យស្របតាមគោលការណ៍ ។<br>– ស្នើសុំរដ្ឋាភិបាលបន្ត និងបង្កើនការវិភាជន៍ ថវិកាជាតិ លើវិស័យក្នុងការអប់រំ ការថែទាំសុខភាព សេវាគាំពារសង្គម និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយធានាថាតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសកុមារ និងជនងាយរងគ្រោះត្រូវបានផ្តល់អាទិភាព។ |